# ជូនចំពោះនិវេសនជននៅ Lawrence៖

ប្រសិនបើ អ្នកយឺតក្នុងការបង់ថ្លៃជួលផ្ទះ ឬប្រឈមនឹងការបណ្ដេញចេញពីផ្ទះ
អ្នកអាចប្រើឯកសារនេះដើម្បីស្វែងរកព័ត៌មានក្នុងការការពារខ្លួនរបស់អ្នក នឹងស្វែងរកជំនួយផ្សេងទៀត។

---

## តើខ្ញុំអាចធ្វើអ្វី បើខ្ញុំហួសពេលបង់ថ្លៃជួលផ្ទះ?

សូមកុំរើចេញពីផ្ទះ!'
អ្នកមានសិទ្ធិស្នាក់នៅក្នុងផ្ទះរបស់អ្នក
នឹងដាក់ពាក្យស្នើសុំជំនួយថ្លៃជួលផ្ទះរបស់អ្នក។
មានកម្មវិធីផ្សេងៗជួយក្នុងការបង់ថ្លៃជួលផ្ទះ
ឬការបញ្ចាំ
ក៏ដូចជាចំណាយលើការប្រើប្រាស់និងចំណាយលើការរើចេញ។

- អ្នកជួលដែលមានសិទ្ធិអាចទទួលបានជំនួយថ្លៃជួលផ្ទះរហូតដល់ 15 ខែ
ផ្អែកតាមកម្មវិធីថ្មីរបស់រដ្ឋសហព័ន្ធពីជំនួយលើថ្លៃជួលផ្ទះបន្ទាន់ (ERAP)។
អ្នកជួលអាចប្រើផ្ទះស្នាក់នៅរហូតដល់ 12 ខែសម្រាប់ការហួសបង់ប្រាក់ជួល និងប្រើជំនួយ 3 ខែនៅពេលជួលផ្ទះនាអនាគត។

- អ្នកជួលនិងម្ចាស់ផ្ទះដែលមានសិទ្ធិអាចទទួលប្រាក់រហូតដល់ $10,000 ដើម្បីបង់ថ្លៃជួលដែលលើស
ឬការបញ្ចាំនាពេលអនាគត
ឬការជួលក្រោមកម្មវិធីជំនួយនិវេស្សនជនសម្រាប់គ្រួសារផ្លាស់ប្តូរលំនៅ (RAFT)
និងជំនួយលើការបញ្ចាំនិងការជួលបន្ទាន់ (ERMA)។

ដើម្បីស្នើសុំសម្រាប់កម្មវិធីទាំងនេះ
សូមទូរស័ព្ទទៅលេខ 800-224-5124 ឬទៅកាន់ to cognitoforms.com/CommunityTeamwork1/RAFTERMAApplicationCTI

## តើខ្ញុំអាចធ្វើអ្វី បើម្ចាស់ផ្ទះបានផ្ញើ “សេចក្តីជូនដំណឹងឱ្យចាកចេញ” បណ្តេញខ្ញុំចេញ?

សេចក្តីជូនដំណឹងឱ្យចាកចេញ
គឺប្រាប់ឱ្យអ្នកត្រូវចាកចេញពីផ្ទះរបស់អ្នកនៅកាលបរិច្ឆេទជាក់លាក់ណាមួយ។
អ្នកមិនត្រូវរើចេញតាមកាលបរិច្ឆេទលើសេចក្តីជូនដំណឹងនោះទេ។
ក្រោយបរិច្ឆេទនៅលើសេចក្តីជូនដំណឹងកន្លងទៅ
ប្រសិនបើម្ចាស់ផ្ទះចង់បណ្តេញអ្នកចេញ
ពួកគេត្រូវប្តឹងអ្នកទៅតុលាការ។
វាគឺជាអំពើខុសច្បាប់បើម្ចាស់ផ្ទះបណ្តេញអ្នកចេញដោយពុំបានប្តឹងទៅតុលាការ។

## តើខ្ញុំអាចធ្វើអ្វីបើខ្ញុំទទួលបានការតំឡើងថ្លៃជួលផ្ទះ?

ប្រសិនបើអ្នកស្នាក់ផ្ទះឯកជន
ឬផ្ទះពុំមានការឧបត្ថម្ភធនពីរដ្ឋ
នោះម្ចាស់ផ្ទះរបស់អ្នកអាចដំឡើងថ្លៃជួលតាមដែលគេចង់បាន។ បើ
អ្នកទទួលបានសេចក្តីជូនដំណឹងដំឡើងថ្លៃជួល
អ្នកអាចព្យាយាមចរចាតម្លៃសមរម្យជាមួយម្ចាស់ផ្ទះ។
អ្នកអាចរួមគ្នាជាមួយអ្នកជួលផ្សេងទៀតដើម្បីចរចារួមគ្នាជាមួយម្ចាស់ផ្ទះ។ ប្រសិនបើអ្នកមានភតិសន្យា
ម្ចាស់ផ្ទះមិនអាចដំឡើងថ្លៃជួលក្នុងអំឡុងពេលនៃភតិសន្យាទេ។

## តើម្ចាស់ផ្ទះផ្ញើ “សេចក្តីជូនដំណឹងឱ្យចាកចេញ” ដោយទម្រង់ត្រឹមត្រូវឬទេ?

បើម្ចាស់ផ្ទះបណ្តេញអ្នកចេញពីផ្ទះ
ដោយអ្នកមិនបានបង់ថ្លៃជួល ពួកគេ
ត្រូវផ្ញើសេចក្តីជូនដំណឹងឱ្យចាកចេញក្នុងទម្រង់ពិសេសឱ្យអ្នក។
ទម្រង់នេះប្រាប់អ្នកពីអ្វីដែលជួយអ្នកពីការបណ្តេញចេញ។ បើម្ចាស់ផ្ទះមិនបានផ្ញើទម្រង់នេះទេ
គេមិនអាចដាក់បណ្តឹងបណ្តេញអ្នកចេញទៅតុលាការបានទេ។ សូមពិគ្រោះជាមួយមេធាវី។
មានព័ត៌មានសម្រាប់ទំនាក់ទំនងជំនួយផ្នែកច្បាប់
ដោយពុំគិតថ្លៃនៅខាងក្រោយនៃឯកសារនេះ។

## តើខ្ញុំត្រូវបានការពារដោយច្បាប់ជាតិស្តីពីការពន្យាពេល ការបណ្តេញចេញឬទេ?

ច្បាប់ជាតិស្តីពីការផ្អាកការបណ្តេញចេញ
បញ្ឈប់ម្ចាស់ផ្ទះពីការបណ្តេញអ្នកជួលខ្លះ
ដែលមិនអាចជួលបន្តបាន។
វាត្រូវបានដាក់ចេញដោយមជ្ឈមណ្ឌលគ្រប់គ្រងជំងឺឆ្លង (CDC)។ ប្រសិនបើ អ្នកផ្ញើលិខិតប្រកាសរបស់ CDC ទៅម្ចាស់ផ្ទះ
នោះម្ចាស់ផ្ទះមិនអាចបណ្តេញអ្នកចេញរហូតដល់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2021។
ចូរសិក្សាថាតើអ្នកត្រូវបានការពារដោយច្បាប់នេះ
នឹងចូរប្រើទម្រង់នេះដើម្បីផ្ញើទៅកាន់ម្ចាស់ផ្ទះនូវលិខិតប្រកាសរបស់ CDC:
apps.suffolklitlab.org/run/cdc_moratorium/#/1

## តើខ្ញុំអាចធ្វើអ្វី បើខ្ញុំទទួលបាន “ដីកាកោះនិងបណ្តឹង”នៃការបណ្តេញចេញពីតុលាការ?

កុំរើចេញពីផ្ទះ!
ទាក់ទងទៅកាន់មេធាវីដើម្បីសុំជំនួយ។
អ្នកមានសិទ្ធិស្របច្បាប់។
ភ្លាមៗក្រោយពីបានទទួលដីកាកោះនិងពាក្យបណ្តឹង
ចូរបំពេញចម្លើយនិងទម្រង់ស្វែងរក។

- ទម្រង់ចម្លើយប្រាប់ពីរឿងរ៉ាវរបស់អ្នក
- ទម្រង់ពាក្យសម្រាប់ចម្លើយផ្តល់ដល់អ្នកនូវឱកាសប្រាប់គណៈវិនិច្ឆ័យអំពីរឿងហេតុពីខាងរបស់អ្នក
- ទម្រង់ស្វែងរកអនុញ្ញាតឱ្យអ្នកទទួលបានព័ត៌មានដើម្បីបង្ហាញរឿងរ៉ាវរបស់អ្នក

ត្រឡប់ទំព័រនេះឡើងដើម្បីមើលព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក →

ចូរប្រើឧបករណ៍អនឡាញងាយស្រួលប្រើនេះ ដើម្បីបំពេញនិងដាក់ទម្រង់ចម្លើងនិងទម្រង់ស្វែងរកទៅកាន់តុលាការ។ វាពុំគិតថ្លៃ! អ្នកអាចបំពេញនៅលើទូរស័ព្ទដៃនៅទំព័រ www.gbls.org/MADE.

## តើម្ចាស់ផ្ទះអាចបណ្តេញខ្ញុំចេញទេ បើខ្ញុំបានស្នើសុំជំនួយលើការជួលផ្ទះ?

ប្រសិនបើអ្នកត្រូវបានបណ្តេញចេញដោយមិនបង់ថ្លៃជួល ហើយអ្នកស្នើសុំជំនួយណាមួយ តុលាការត្រូវបញ្ឈប់ការបណ្តេញចេញរបស់អ្នក រហូតដល់ភ្នាក់ងារផ្តល់ជំនួយយល់ព្រមឬបដិសេធពាក្យស្នើសុំរបស់អ្នក។ ការបញ្ឈប់ករណីរបស់អ្នកនេះ ហៅថា "ការលើកពេលវេលា។"

## តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំនៅក្នុងតុលាការស្រុក?

ប្រសិនបើករណីរបស់អ្នកស្ថិតក្នុងតុលាការស្រុក អ្នកអាចស្នើសុំផ្ទេរទៅតុលាការលំនៅឋាន ដែលអ្នកអាចទទួលបានជំនួយច្រើនលើករណីរបស់អ្នក។ ចូរប្រើទម្រង់ស្នើផ្ទេរនេះ៖ masslegalhelp.org/housing/lt1-booklet-5-transfer.pdf

## តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំនៅក្នុងតុលាការលំនៅឋាន?

ប្រសិនបើអ្នកនៅតុលាការលំនៅឋាន សូមស្នើតុលាការឱ្យអ្នកទាក់ទងទៅមេធាវីនៃកម្មវិធីថ្ងៃនេះ (Day Program)។ ប្រសិនបើអ្នកមានសិទ្ធិទទួលបានជំនួយដោយពុំគិតថ្លៃ មេធាវីនឹងដំណាងឱ្យអ្នកនៅតុលាការ។

## តើខ្ញុំអាចធ្វើអ្វី បើខ្ញុំត្រូវបានបង្ខំឱ្យចុះកិច្ចព្រមព្រៀង?

ប្រសិនបើម្ចាស់ផ្ទះផ្តល់ឱ្យអ្នកនូវកិច្ចព្រមព្រៀងក្រៅតុលាការ ឬប្រសិនបើអ្នកនៅក្នុងនីតិវិធីផ្សះផ្សាតុលាការ ចូរស្វែងរកជំនួយផ្នែកច្បាប់។ ត្រូវមានការជូនយោបល់ផ្នែកច្បាប់មុនពេលអ្នកចុះកិច្ចព្រមព្រៀងជាមួយម្ចាស់ផ្ទះឬមេធាវីរបស់ពួកគេ។ មេធាវីម្ចាស់ផ្ទះដំណាងឱ្យម្ចាស់ផ្ទះ មិនមែនដំណាងឱ្យអ្នកទេ។ អ្នកមិនមានកាតព្វកិច្ចចុះហត្ថលេខាណាមួយទេ។

## តើខ្ញុំត្រូវធ្វើដូចម្តេចបើម្ចាស់ផ្ទះមិនប្តឹងខ្ញុំទៅតុលាការ ប៉ុន្តែបង្ខំឱ្យខ្ញុំចេញពីផ្ទះដោយវិធីផ្សេង?

នេះគឺជាទង្វើខុសច្បាប់។ អ្នកអាចស្នើឱ្យចៅក្រមចេញបញ្ជាទៅម្ចាស់ផ្ទះឱ្យបញ្ឈប់រាល់អំពើខុសច្បាប់ ដូចជា ចាក់សោរ បិទការប្រើប្រាស់ទឹកភ្លើង ឬបដិសេធការជួសជុលបន្ទាន់ផ្សេងៗ។ ដើម្បីបានដីកានេះ៖ អ្នកត្រូវដាក់បណ្តឹងស្នើសុំដីការឹតបន្តឹងបណ្តោះអាសន្ន (TRO)។ ចូរទៅកាន់ CourtFormsOnline នៅ massaccess.suffolklitlab.org ដើម្បីបំពេញទម្រង់ TRO។ ទូរស័ព្ទស្វែងរកជំនួយផ្នែកច្បាប់។ អ្នកក៏អាចរាយការណ៍ម្ចាស់ផ្ទះរបស់អ្នកទៅកាន់ការិយាល័យរដ្ឋអាជ្ញា ដោយទូរស័ព្ទទៅលេខ (617) 727-8400។

# ការស្វែងរកជំនួយ

### អង្គការ **Northeast Legal Aid**

ផ្តល់នូវជំនួយផ្នែកច្បាប់ដោយពុំគិតថ្លៃ ប្រសិនបើអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងអាចជួបមេធាវីសម្រាប់កម្មវិធី (Day Program) នៅតុលាការលំនៅឋានភាគឦសាន្ត
ទូរស័ព្ទ: (800) 336-2262 or 978-458-1465
ដាក់ឈ្មោះ អាសយដ្ឋាន និងវិធីដែលអាចទាក់ទងអ្នកបាន
អ៊ីម៉ែល: LawyerForDay@nla-ma.org.
ស្នើសុំតាមអនឡាញ: NortheastLegalAid.org/get-legal-help

### ក្រុមការងារសហគមន៍ **Lawrence**

ផ្តល់ជូនមជ្ឈមណ្ឌលស្ថេរភាពលំនៅឋាន ដើម្បីជួយប្រសិនបើអ្នកកំពុងប្រឆាំងនឹងការបណ្តេញចេញពីផ្ទះ
ទូរស័ព្ទ: (978) 685-3115
អ៊ីម៉ែល: info@lawrencecommunityworks.org

### អង្គការ **ACT Lawrence**

ផ្តល់សេវាប្រឹក្សាយោបល់លំនៅឋាននិងហិរញ្ញវត្ថុដោយពុំគិតថ្លៃ
ទូរស័ព្ទ: (978) 685-6274
អ៊ីម៉ែល: reception@actlawrence.org
ស្នើសុំតាមអនឡាញ: ចូរប្រើទម្រង់ទំនាក់ទំនងពួកយើង នៅប៊ូតុងខាងក្រោមនៃគេហទំព័រ ActLawrence.org

### ក្រុមការងារសហគមន៍ **(Community Teamwork)**

ផ្តល់ជំនួយជួលផ្ទះនិងត្រូវសងវិញនៅពេលក្រោយ និងការជួលនាអនាគត
ទូរស័ព្ទ: (978) 459-0551, (800) 698-0551,
អ៊ីម៉ែល: CovidResponseCTI@commteam.org
ស្នើសុំតាមអានឡាញ: cognitoforms.com/CommunityTeamwork1/RAFTERMAApplicationCTI

### ក្រុមប្រឹក្សាសកម្មភាពសហគមន៍ **Lawrence**

ដំណើរការកម្មវិធីជំនួយជួលផ្ទះបន្ទាន់នៅ Lawrence
ទូរស័ព្ទ: (978) 620-4993
អ៊ីម៉ែល: esgcovid@glcac.org
ទទួលយកពាក្យស្នើសុំពីគេហទំព័ររបស់គេ: glcac.org/departments/Housing-Assistance.html

### សហគមន៍សប្បុរសធម៌កាតូលិក

ផ្តល់ជំនួយលើថ្លៃជួលផ្ទះ ការប្រើប្រាស់ និងចំណាយផ្សេងៗទៀត ទូរស័ព្ទ: (781) 593-2312

ផលិតដោយគម្រោងជំនួយផ្នែកច្បាប់លើការបណ្តេញចេញក្នុងអំឡុងពេល *COVID (CELHP)* និងអង្គការ *Northeast Legal Aid* ខែមេសា ឆ្នាំ*2021* សម្រាប់ព័ត៌មានបន្ថែម ចូលទៅកាន់ *EvictionLegalHelp.org*